ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * *

ឆ្នាំទី ៤ លេខ ២១ ថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ១៩៩៦

រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្តីសំរេច
- សារាចរ

ផ្សាយចេញពីទីស្តីការគណៈរដ្ឋមន្ត្រីរៀងរាល់សប្តាហ៍

មាតិកា

I .ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

១៥-៥-១៩៩៦- ព្រះរាជក្រឹត្យ ជស/រកត/០៥៩៦/២២ តែងតាំងអ្នកអង្គម្ចាស់ ក្សត្រិយ៍ ជាទីប្រឹក្សាសម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី ១ ៨៧៧

០៥-៦-១៩៩៦- ព្រះរាជក្រឹត្យ ជស/រកត/០៦៩៦/២៤ តែងតាំងឯកឧត្តម **ត្រាក់ ថៃសៀង** ជាទីប្រឹក្សាឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសាធារណការ និង ដឹកជញ្ជូន ៨៧៨

០៥-៥-១៩៩៦- ព្រះរាជក្រឹត្យ ជស/រកត/០៦៩៦/២៥ តែងតាំងឯកឧត្តម **តាន់ ស៊ីមឃន** ជាទីប្រឹក្សាឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ៨៧៩

០៥-៦-១៩៩៦- ព្រះរាជក្រឹត្យ ជស/រកត ០៦៩៦/២៦ តម្លើងឋានន្តរសក្តិថ្នាក់ ឧត្តមសេនីយ៍ត្រី ជាកិច្ចបច្ឆាមរណៈជូនសពលោក វរសេនីយ៍ឯក **នុត ប៊ុនណាត** ៨៨០

០៥-៦-១៩៩៦- ព្រះរាជក្រឹត្យ ជស/រកត/០៦៩៦/២៧ តម្លើងឋានន្តរសក្តិថ្នាក់ ឧត្តមសេនីយ៍ទោ ជាកិច្ចបច្ឆាមរណៈជូនសពលោក ឧត្តមសេនីយ៍ត្រី **ស៊ីមប៊ូល** ៨៨២

០៦-៦-១៩៩៦- ព្រះរាជក្រឹត្យ ជស/រកត/០៦៩៦/២៨ តែងតាំងឯកឧត្តម **សេង រ៉ុន** ជាទីប្រឹក្សាផ្ទាល់របស់ឯកឧត្តម ឡយ ស៊ីមឈាង អនុប្រធានទី ១ នៃរដ្ឋសភា ៨៨៣

២៧-៥-១៩៩៦- ព្រះរាជក្រឹត្យ NS/KRT/34~បង្កើតក្រសួងព្រះបរមរាជវាំង ៨៨៤

៣០–៥–១៩៩៦– ព្រះរាជក្រឹត្យ NS/KRT/0596/36 ៨៨៥
០៣–៦–១៩៩៦– ព្រះរាជក្រឹត្យ នស/រកត/០៦៩៦/៣៧ តែងតាំងលោក
ឡេង ឫទ្ធី ជាឧកញ៉ា ៨៨៦
០៣–៦–១៩៩៦– ព្រះរាជក្រឹត្យ នស/រកត/០៦៩៦/៣៨ តែងតាំងលោក
ម៉ៃ ឫទ្ធី ជាឧកញ៉ា ៨៨៧
០៥–៦–១៩៩៦– ព្រះរាជក្រឹត្យ នស/រកត/០៦៩៦/៣៩ តែងតាំងលោក
ម៉ៅ សំអឿន ជាអ្នកឧកញ៉ា ៨៨៨

II - ទីស្តីការគណៈរដ្ឋមន្ត្រី

១-អនុក្រឹត្យ

០៦–៦–១៩៩៦ – អនុក្រឹត្យលេខ ១០៣ អនក្រ.តត ស្តីពីការផ្តល់មេដាយស្ថាបនាជាតិ ៨៨៩
០៦–៥–១៩៩៦ – អនុក្រឹត្យលេខ ១០៤ អនក្រ.តត ស្តីពីការផ្តល់មេដាយស្ថាបនាជាតិ ៨៩០

២ -ផែនការណែនាំ

០៥–៦–១៩៩៦ – ផែនការណែនាំលេខ ០៣ ផណន ស្តីពីការចាត់តាំងរៀបចំ
ពិធីបុណ្យចំរើនព្រះជន្មសម្តេចព្រះរាជអគ្គមហេសី នរោត្តម
មុនីនាថ សីហនុ ក្នុងគម្រប់ព្រះជន្ម ៦០ យាងចូល ៦១ព្រះវស្សា ៨៩១

III - ការងារបណ្តាក្រសួង

១ - ទីស្តីការរដ្ឋមន្ត្រី ក្រសួងពត៌មាន

ប្រកាស

០៣–៦–១៩៩៦ – ប្រកាសលេខ ១៤៦/៩៦ ពម.ប្រក.បល ស្តីពីការតែងតាំង
មន្ត្រីរាជការ ៨៩៣

០៣-៦-១៩៩៦ - ប្រកាសលេខ ១៤៧/៩៦ ពម.ប្រក អនុញ្ញាតជូនលោក **ចូវ ចុងឈាន់** បើកគ្រឹះស្ថានបោះពុម្ពផ្សាយ «ហ្សៀតអេស៊ីយ៉ាគ្រុប» ៨៩៤

២ - ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

ប្រកាស

០៣-៦-១៩៩៦ - ប្រកាសលេខ ៤៣០ អយក.ប្រក ស្តីពីការប្តូរឈ្មោះអនុវិទ្យាល័យមហាសៀក ទៅជា «អនុវិទ្យាល័យមហាមង្គល **ហ៊ុន សែន**» ស្ថិតនៅក្នុងឃុំខ្វង ស្រុកកោះសូទិន ខេត្តកំពង់ចាម ៨៩៥

០៥-៦-១៩៩៦ - ប្រកាសលេខ ៤៣៦ អយក.ប្រក ស្តីពីការបើកសាលាបឋមសិក្សាចំណេះទូទៅ ឯកជនខ្មែរ ចិន ៨៩៧

៣ - ទីស្តីការរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ

ប្រកាស

០៤-៦-១៩៩៦ - ប្រកាសលេខ ៣២៩ ប្រក.កសក.ចត ស្តីពីការបង្កើតមជ្ឈមណ្ឌលឯកសារវិទ្យាល័យសាស្ត្របច្ចេកទេសកសិកម្ម ៨៩៩

០៤-៦-១៩៩៦ - ប្រកាសលេខ ៣២៨ ប្រក.កសក.ចត ស្តីពីការបំបែកមូលដ្ឋានជាពីរ ៩០០

០៧-៦-១៩៩៦ - ប្រកាសលេខ ៣៣២ ប្រក.កសក ស្តីពីការជួលទីតាំងមជ្ឈមណ្ឌលចិញ្ចឹមជ្រូក នៅគីឡូម៉ែត្រលេខ ១១ និងមជ្ឈមណ្ឌលចិញ្ចឹមមាន់ព្រែកសំរោង ទៅក្រុមហ៊ុន CP.Cambodia CO LTD ៩០២

២៥

៤ - រដ្ឋលេខាធិការដ្ឋាន មុខងារសាធារណៈ

សេចក្តីសំរេច

០៤-៦-១៩៩៦- សេចក្តីសំរេចលេខ ៣៥៦ សសរ.មស.ក្រខ ស្តីពីការបែងចែក សិស្សនិស្សិតចំនួន ៤២៩នាក់ ដែលទើបបញ្ចប់ការសិក្សាក្នុង និងក្រៅប្រទេស ៩០៤

I - ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

ព្រះរាជក្រឹត្យ ជស/រកត/០៥៩៦/២២

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស
ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ
បរមបពិត្រ ព្រះចៅក្រុងកម្ពុជាធិបតី

* * *

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ១៩៩៦

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងអ្នកអង្គម្ចាស់ - អ្នកអង្គម្ចាស់ក្សត្រិយ៍ ដូចមានរាយព្រះនាមខាងក្រោមនេះ

ជាទីប្រឹក្សា សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** នាយករដ្ឋមន្ត្រីទី ១ នៃរាជរដ្ឋាភិបាលកម្ពុជា ដោយមាន ឋានៈស្មើអនុរដ្ឋលេខាធិការ ÷

- អ្នកអង្គម្ចាស់ **ស៊ីសុវត្ថិ ក្បុលធ័ត** ជាទីប្រឹក្សាទទួលបន្ទុកកិច្ចការសំណង់ និងនគរូបនីយកម្ម

- អ្នកអង្គម្ចាស់ក្សត្រិយ៍ **ស៊ីសុវត្ថិ អេរ៉ាវ៉ាឌី** ជាទីប្រឹក្សាទទួលបន្ទុកកិច្ចការអប់រំយុវជននិងកីឡា

មាត្រា ២ : នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះ រាជក្រឹត្យនេះអោយបានសំរេច ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ,ថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ១៩៩៦

ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាដ៏ខ្ពង់ខ្ពស់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

* * *

ព្រះរាជក្រឹត្យ ជស/ រកត / ០៦ ៩៦ / ២៤

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រីទី ១ នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ១៩៩៦

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងឯកឧត្តម **ត្រាក់ ថៃសៀង** ជាទីប្រឹក្សាឯកឧត្តម ឧបនាយករដ្ឋមន្ត្រី - រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូនទទួលបន្ទុកការងារគ្រប់គ្រង និងទំនាក់ទំនងអន្តរជាតិ មានឋានៈស្មើអនុរដ្ឋលេខាធិការ ÷

មាត្រា ២ : នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះ រាជក្រឹត្យនេះអោយបានសំរេច ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ,ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ១៩៩៦

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

* * *

ព្រះរាជក្រឹត្យ ជស/ រកត / ០៦៩៦ / ២៥

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

- យោងតាមសំណើររបស់នាយករដ្ឋមន្ត្រីទី ១ នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ១៩៩៦

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងឯកឧត្តម **តាន់ ស៊ុមយន** ជាទីប្រឹក្សាឯកឧត្តម ឧបនាយករដ្ឋមន្ត្រី - រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ទទួលបន្ទុកការងារ និងកំណត់គោលការណ៍ដឹកជញ្ជូនគ្រប់ប្រភេទ មានឋានៈស្មើអនុរដ្ឋលេខាធិការ ÷

មាត្រា ២ : នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះអោយបានសំរេច ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ,ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ១៩៩៦

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

* * *

ព្រះរាជក្រឹត្យ ជស/ រកត / ០៦ ៩៦ / ២៦

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋមន្ត្រីក្រសួងការពារជាតិ

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតម្លើងឋានន្តរសក្តិ ឧត្តមសេនីយ៍ត្រី ជាកិច្ចបច្ចាមរណៈជូនសពលោក ÷

- វរសេនីយ៍ឯក **នុត ម៉ុនណាត** អត្តលេខ ០០០៣០២ នាយសេនាធិការរងកងអាកាសចរ ខេមរភូមិន្ទ ។

មាត្រា ២ : នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា និង ជាសហអគ្គបញ្ជាការកងយោធពលខេមរភូមិន្ទ ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះអោយបានសំរេច ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ,ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ១៩៩៦
ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់
ប្រមុខរដ្ឋស្តីទី
ហត្ថលេខា
ជា ស៊ីម

* * *

ព្រះរាជក្រឹត្យ ជស/រកត/ ៩៦/២៧

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

* * *

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋមន្ត្រីក្រសួងការពារជាតិ

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតម្លើងឋានន្តរសក្តិ ឧត្តមសេនីយ៍ទោ ជាកិច្ចបច្ឆាមរណៈជូនសពលោក ÷

- ឧត្តមសេនីយ៍ត្រី **ស៊ឹម ប៊ូល** អត្តលេខ ០០០១៣៨ មេបញ្ជាការកងពលធំលេខ ៣។

មាត្រា ២ : នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា និង ជាសហអគ្គមេបញ្ជាការ នៃកងយោធពល ខេមរភូមិន្ទ ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះអោយបានសំរេច ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ,ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ១៩៩៦

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

* * *

ព្រះរាជក្រឹត្យ ជស/រកត/០៦៩៦/២៨

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- យោងតាមសេចក្តីសំរេចរបស់រដ្ឋសភា ស្តីពីការជ្រើសតាំងសម្តេច **ជា ស៊ីម** ជាប្រធានរដ្ឋសភា ឯកឧត្តម **ឡូយ ស៊ីមឈាង** ជាអនុប្រធានទី ១ នៃរដ្ឋសភា នាសម័យប្រជុំពេញអង្គលើកទី ១ នីតិកាលទី ១ ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ១៩៩៣
- យោងតាមសំណើរបស់ប្រធានរដ្ឋសភាស្តីទី ចុះថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ១៩៩៦

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងឯកឧត្តម **សេង វ៉ុន** ជាទីប្រឹក្សាផ្ទាល់របស់ឯកឧត្តម **ឡូយ ស៊ីមឈាង** អនុប្រធានទី ១ នៃរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើរដ្ឋលេខាធិការ ។

មាត្រា ២ : នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ព្រមទាំងអគ្គលេខាធិការរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះអោយបានសំរេច ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ,ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ១៩៩៦

ក្នុងព្រះបរមនាម និងតាមព្រះរាជគ្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

* * *

ព្រះរាជក្រឹត្យ NS/KRT-34

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើ នៅថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣
- បានទ្រង់យល់ ព្រះរាជក្រឹត្យ **NS/KRT/1194/08** ចុះថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤ ស្តីពីការតែងតាំង ឯកឧត្តមឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីព្រះបរមរាជវាំង ជាអ្នកឧកញ្ញា ចៅហ្វាវាំង
- បានទ្រង់យល់ នូវ សេចក្តីត្រូវការចាំបាច់

ត្រាស់បង្គាប់

មាត្រា ១ : បង្កើតក្រសួងព្រះបរមរាជវាំង ដើម្បីចាត់ចែងគ្រប់ការងារ ថ្វាយព្រះមហាក្សត្រ ។

មាត្រា ២ : រចនាសម្ព័ន្ធចាត់តាំងរបស់ ក្រសួងព្រះបរមរាជវាំង ចែកចេញជា ១០ នាយកដ្ឋាន :

១- នាយកដ្ឋាន រដ្ឋបាល

២- នាយកដ្ឋានទំនាក់ទំនង

៣- នាយកដ្ឋាន អភិរក្ស

៤- នាយកដ្ឋាន ផែនការ គណនេយ្យ

៥- នាយកដ្ឋាន គ្រប់គ្រងព្រះរាជដំណាក់ និង ជីវភាព

៦- នាយកដ្ឋាន ឧបត្ថម្ភ និង សង្គ្រោះប្រជារាស្ត្រ

៧- នាយកដ្ឋាន ដឹកជញ្ជូន

៨- នាយកដ្ឋាន សំណង់

៩- នាយកដ្ឋាន ពិធីការ

១០- នាយកដ្ឋាន កងរក្សាព្រះអង្គ

មាត្រា ៣ : ប្រគល់ជូន ឯកឧត្តមឧបនាយករដ្ឋមន្ត្រី និងជា រដ្ឋមន្ត្រីព្រះបរមរាជវាំង រៀបចំ និង កំណត់តួនាទីភារកិច្ច នៅក្នុងក្រសួងព្រះបរមរាជវាំង ។

មាត្រា ៤ : នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះ រាជក្រឹត្យនេះអោយបានសំរេច ។

មាត្រា ៥ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានបញ្ញត្តិ ចាប់ពីពេលឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ,ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ១៩៩៦

ព្រះហស្តលេខា

នរោត្តម សីហនុ

KRET NS/KRT/0596/36

NOUS

Norodom Sihauouk

Roi du Cambodge

NOMMONS

Monsieur Philippe PIEL :

Chevalier de l'ordre du SAHAMETREI

Fait le 30 Mai 1996

Sa. Majesté a Signé

Norodom Sihanouk

ព្រះរាជក្រឹត្យ នស/រកត/០៦៩៦/៣៧

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា

តែងតាំង

លោក ឡេង មុន្នី

ជា

ឧកញ៉ា

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ១៩៩៦

ព្រះហស្ថលេខា

នរោត្តម សីហនុ

*   *   *

ព្រះរាជក្រឹត្យ នស/រកត/០៦៩៦/៣៨

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា

តែងតាំង

លោក ម៉ៃ ឧត្តី

ជា

ឧកញ៉ា

ធ្វើនៅព្រះរាជវាំងភ្នំពេញ, ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ១៩៩៦

ព្រះហស្តលេខា

នរោត្តម សីហនុ

* * *

ព្រះរាជក្រឹត្យ នស/រកត/០៦៩៦/៣៩

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា

តែងតាំង

លោក ឃ៉ោ សំអឿន

ជា

អ្នកឧកញ៉ា

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ១៩៩៦

ព្រះហស្តលេខា

នរោត្តម សីហនុ

* * *

II - ឯកសារគណៈរដ្ឋមន្ត្រី

១_អនុក្រឹត្យ

រាជធានីភ្នំពេញ,ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ : ១០៣ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាល ខេត្តកណ្តាល

សម្រេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយមាស ស្ថាបនាជាតិ ជូនចំពោះលោក **ឃូ សាន្ត** ប្រធានក្រុមហ៊ុនស៊ីន អ៊ីលីមីតធីត ដែលបានជួយកសាងផ្លូវជួសជុលពង្រីកក្រាលគ្រួសក្រហម នៅផ្លូវស្រែអំពិល ភូមិ ពពាលខែ ឃុំដីអិដ្ឋ ស្រុកកៀនស្វាយ ខេត្តកណ្តាល អស់ទឹកប្រាក់ ៤៤.៥០០ $US ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្ត កណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១ **នាយករដ្ឋមន្ត្រីទី ២**

ព្រះហស្តលេខា និងត្រា ហត្ថលេខា និងត្រា

នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ១០៤ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា .
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស.រកត.១០៩៥.០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកណ្តាល

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយមាសស្ថាបនាជាតិ ជូនចំពោះលោក **ឃូ សាន្ត** ប្រធានក្រុមហ៊ុន ស៊ីនអ៊ីលីមីធីត ដែលបានបរិច្ចាគប្រាក់ ៤៥.០០០ ដុល្លារអាមេរិក សំរាប់កសាងផ្លូវ និង ឧបត្ថម្ភប្រាក់គោលនយោបាយជូនប្រជារាស្ត្រ នៅផ្លូវស្រែអំពិល ភូមិពពាលខែ ឃុំធីអិដ្ឋ ស្រុកកៀនស្វាយ ខេត្តកណ្តាល ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

២_ផែនការណែនាំ

រាជធានីភ្នំពេញ , ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ១៩៩៦

ផែនការណែនាំលេខ : ០៣ ផណន

ស្តីពីការចាត់តាំងរៀបចំពិធីបុណ្យចំរើនព្រះជន្មសម្តេច

ព្រះរាជអគ្គមហេសី នរោត្តម មុនីនាថ សីហនុ ក្នុងគម្រប់ព្រះជន្ម

៦០ យាងចូល ៦១ ព្រះវស្សា

* * *

ព្រះរាជពិធីបុណ្យចំរើនព្រះជន្មសម្តេចព្រះរាជអគ្គមហេសី **នរោត្តម មុនីនាថ សីហនុ** ជាទីគោរព សក្ការៈដ៏ខ្ពង់ខ្ពស់ក្នុងគម្រប់ព្រះជន្ម ៦០ យាងចូល ៦១ ព្រះវស្សា នឹងត្រូវប្រព្រឹត្តទៅ នៅថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ ១៩៩៦ ខាងមុននេះ ។

ដើម្បីសំដែងនូវកតញ្ញូតាធម៌ តបស្នងសងព្រះមហាករុណាធិគុណដ៏ខ្ពង់ខ្ពស់ ក្នុងមនោ - សញ្ចេតនា គោរពស្រឡាញ់ ដឹងគុណយ៉ាងជ្រាលជ្រៅ និង ដើម្បីចូលរួមអបអរសាទរ ថ្វាយព្រះពរ ស័ព្ទសាធុការបវរមហាប្រសើរ សូមមានព្រះជន្មាយុយឺនយូរ មានព្រះសុខមាលភាពល្អបរិបូណ៌ ចំពោះសម្តេចព្រះរាជអគ្គមហេសីជាទី គោរពសក្ការៈ ក្នុងឱកាសព្រះរាជពិធីបុណ្យចំរើនព្រះជន្ម របស់ព្រះអង្គគម្រប់ ៦០ យាងចូល ៦១ ព្រះវស្សានោះ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សូមធ្វើការណែនាំដូចតទៅនេះ ÷

១–គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន អង្គភាព រាជធានីភ្នំពេញ សាលាខេត្ត ក្រុង សាលារៀន រោងចក្រសហគ្រាស និងគ្រឹះស្ថានក្រុមហ៊ុនឯកជន ត្រូវរៀបចំតុបតែងលំអ ទង់ជាតិ ទង់ក្អែប បដាពាក្យស្លោក តាំងព្រះឆាយាលក្ខណ៍សម្ដេចព្រះរាជអគ្គមហេសី **នរោត្ដម មុនីនាថ សីហនុ** មានតាំងភ្លើងពណ៌ និង មានពាក្យ ស្លោកថ្វាយព្រះពរ ។

២–គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន រាជធានីភ្នំពេញ និង គ្រប់ខេត្ត–ក្រុង ត្រូវធ្វើលិខិតថ្វាយព្រះពរ ថ្វាយសម្ដេចព្រះរាជអគ្គមហេសី ជាទីគោរពសក្ការៈអោយបានមុនថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ និង ផ្ញើជូនបណ្ដាញសារពត៌មាន ដើម្បីផ្សព្វផ្សាយ ។

៣–ព្រះបរមរាជវាំង ត្រូវចាត់តាំងរៀបចំព្រះរាជពិធីបុណ្យចំរើនព្រះជន្មសម្ដេចព្រះរាជអគ្គមហេសីជាទី គោរពសក្ការៈអោយបានសមស្របទៅនឹងប្រពៃណីសាសនា និង ប្រពៃណី ។

៤–ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈត្រូវធ្វើការណែនាំដល់មន្ទីរវប្បធម៌ខេត្ត–ក្រុង អោយចាត់តាំង សំដែងសិល្បៈជូនមហាជនទស្សនាកំសាន្តនៅតាមទីធ្លាសាធារណៈ នៅថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ ១៩៩៦ តាមពេលវេលាសមស្រប ។

ទទួលបានផែនការណែនាំនេះ គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន រាជធានីភ្នំពេញ និង ខេត្ត ក្រុង ត្រូវចាត់តាំងអនុវត្តអោយទទួលបានលទ្ធផលល្អប្រសើរ នូវការរៀបចំពិធីបុណ្យចំរើនព្រះជន្មសម្ដេចព្រះ រាជអគ្គមហេសី ជាទីគោរពសក្ការៈ ។

ពាក្យស្លោក :

«សូមថ្វាយព្រះពរសម្ដេចព្រះរាជអគ្គមហេសី **នរោត្ដម មុនីនាថ សីហនុ** សូមមានព្រះជន្មាយុយឺនយូរ»

« សូមថ្វាយព្រះពរបវរមហាប្រសើរសម្ដេចម៉ែ មានព្រះជន្មាយុយឺនយូរ និង មានព្រះសុខភាពល្អ បរិបូណ៌ »

នាយករដ្ឋមន្ត្រីទី ១
ព្រះហស្ដលេខានិងត្រា
នរោត្ដម រណឫទ្ធិ

នាយករដ្ឋមន្ត្រីទី ២
ហត្ថលេខានិងត្រា
ហ៊ុន សែន

* * *

III - ការងារបណ្តាក្រសួង

១_ទីស្តីការរដ្ឋមន្ត្រីក្រសួងពត៌មាន

ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ១៩៩៦

ប្រកាសលេខ ១៤៦/៩៦ ពម. ប្រក. បល

ស្តីពីការតែងតាំងមន្ត្រីរាជការ

* * *

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រម ចុះថ្ងៃទី ២០ កក្កដា ឆ្នាំ ១៩៩៤ ប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស.រកម. ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ប្រកាសអោយច្បាប់ ស្តីពីការបង្កើតក្រសួងពតិមាន
- យោងលិខិត ២១០ មស.ក្រខ ចុះថ្ងៃទី ២១ ខែ មីនា ១៩៩៦ របស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ស្តីពីការយល់ព្រមបញ្ចូលក្របខ័ណ្ឌ ១ នាក់ ពីក្រសួងការពារជាតិមកក្រសួង ពតិមាន
- តាមសំណូមពរចាំបាច់របស់មន្ទីរពតិមាន ក្រុងកែប បូកគោ

សំរេច

ប្រការ ១ : តែងតាំងលោក **ម៉ម ឈឿម** ជាអនុប្រធានមន្ទីរពតិមាន ក្រុងកែប បូកគោ ។

ប្រការ ២ : ប្រាក់បៀវត្សប្រាក់ឧបត្ថម្ភផ្សេងៗ របស់លោក **ម៉ម ឈឿម** ត្រូវទទួលនៅមន្ទីរពតិមានក្រុងកែបបូកគោ ចាប់ពីពេលក្រសួងការពារជាតិផ្ទេរផ្តាច់មកក្រសួងពតិមាន ។

ប្រការ ៣ : លោកអគ្គនាយករដ្ឋបាល និង កិច្ចការទូទៅ លោកប្រធានមន្ទីរពត៌មានក្រុងកែប ប៉ូកគោ និងសាមីជនមានភារៈអនុវត្តតាមប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ខៀវ កាញារីទ្ធ

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ១៩៩៦

ប្រកាសលេខ ១៤៧/៩៦ ពម.ប្រក

អនុញ្ញាតជូនលោក ចូវ ធុនណាន់ បើកគ្រឹះស្ថានបោះពុម្ព

ផ្សាយ «ហ្វ្រេត អេស៊ីយ៉ាគ្រុប»

រដ្ឋមន្ត្រីក្រសួងពត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នសរកម.១០-៩៦-១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងពត៌មាន
- យោងលិខិតស្នើសុំអនុញ្ញាតច្បាប់បើកអាជីវកម្មគ្រឹះស្ថានបោះពុម្ពផ្សាយ«ហ្វ្រេតអេស៊ីយ៉ា» របស់លោក **ចូវ ធុនណាន់** ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ១៩៩៦

សំរេច

ប្រការ ១ អនុញ្ញាតជូនលោក **ចូវ ធុនណាន់** បើកគ្រឹះស្ថានបោះពុម្ពផ្សាយ « ហ្វ្រេត អេស៊ីយ៉ាគ្រុប » ដែលមានស្នាក់ការនៅផ្ទះលេខ ៧១៥ អឺអូ ក្រុមទី ១៦ វិថីព្រះមុនីវង្ស សង្កាត់បឹងកេងកង ៣ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

ប្រការ ២ : រាល់ដំណើរការសេវាកម្មបោះពុម្ពផ្សាយត្រូវអនុវត្តតាមកិច្ចសន្យាសមស្របទៅ នឹងទំនៀម ទំលាប់សន្តិសុខសណ្តាប់ធ្នាប់សង្គម និងច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៣ : ក្នុងករណីប្រព្រឹត្តល្មើសដូចមានចែងក្នុងប្រការ ២ សាមីខ្លួនត្រូវទទួលខុសត្រូវតាមច្បាប់ជាធរមាន ។

ប្រការ ៤ : ប្រធាននាយកដ្ឋានគ្រប់គ្រងការបោះពុម្ពផ្សាយ សោតទស្សន៍នៃអគ្គនាយកដ្ឋានរដ្ឋបាល ហិរញ្ញវត្ថុ និងប្រធានមន្ទីរពត៌មានរាជធានីភ្នំពេញ ត្រូវទទួលអនុវត្តតាមភារកិច្ចរៀងៗខ្លួន ។

ប្រការ ៥ : ប្រកាសនេះមានអានុភាពតតិយុត្តិចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ
ហត្ថលេខា និង ត្រា
ខៀវ កាញារីទ្ធ

* * *

២_ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំ_យុវជន និងកីឡា

ប្រកាស

ភ្នំពេញ , ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ១៩៩៦

ប្រកាសលេខ : ៤៣០ អយក.ប្រក

ស្តីពីការប្តូរឈ្មោះ អនុវិទ្យាល័យ មហាសៀក ទៅជា
« អនុវិទ្យាល័យមហាមង្គល ហ៊ុន សែន »ស្ថិតនៅក្នុង
ឃុំមហាខ្ញូង ស្រុកកោះសូទិន ខេត្តកំពង់ចាម

* * *

រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា

– បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជ រដ្ឋាភិបាលកម្ពុជា

- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ កក្កដា ១៩៩៤
- បានឃើញក្រឹត្យ ច្បាប់លេខ ៣០ ក្រច ចុះថ្ងៃទី ២០ វិច្ឆិកា ១៩៨៦ ស្តីពីប្រព័ន្ធ អប់រំចំណេះទូទៅ
- យោងលិខិតរបស់គណៈកម្មការសមាគមមាតាបតាសិស្ស អនុវិទ្យាល័យមហាសៀក ចុះថ្ងៃទី ០១ ឧសភា ១៩៩៦ ដោយមានយោបល់ឯកភាពពីមន្ទីរអប់រំ យុវជន និង កីឡា និង អភិបាលខេត្តកំពង់ចាម
- តាមយោបល់ឯកភាពរបស់ឯកឧត្តមរដ្ឋលេខាធិការនៃក្រសួងអប់រំ យុវជន និង កីឡា ។

សំរេច

ប្រការ ១ : អនុញ្ញាតអោយប្តូរឈ្មោះអនុវិទ្យាល័យមហាសៀកបច្ចុប្បន្នទៅជា «អនុវិទ្យាល័យមហាមង្គល **ហ៊ុន សែន**» ចាប់ពីឆ្នាំសិក្សា ១៩៩៥–៩៦ តទៅ ។

ប្រការ ២ : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៣ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា ប្រធាននាយកដ្ឋានចាត់តាំង ប្រធាននាយកដ្ឋានផែនការ និង ហិរញ្ញកិច្ច នៃក្រសួងអប់រំយុវជន និង កីឡា ប្រធានមន្ទីរអប់រំយុវជន និង កីឡា ខេត្តកំពង់ចាម និង នាយក អនុវិទ្យាល័យមហាមង្គល **ហ៊ុន សែន** មានភារកិច្ចរៀង ៗ ខ្លួនអនុវត្តប្រកាសនេះ ។

ជ-រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា
រដ្ឋលេខាធិការ
ហត្ថលេខា និង ត្រា
គា សាឃាន

* * *

ភ្នំពេញ , ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ១៩៩៦

ប្រកាសលេខ : ៤៣៦ អយក.ប្រក

ស្តីពីការអនុញ្ញាតអោយបើកសាលាបឋមសិក្សា

ចំណេះទូទៅឯកជនខ្មែរ—ចិន

* * *

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះចៅក្រុងកម្ពុជាធិបតី ចុះថ្ងៃទី ០១–១១–១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០–៧–១៩៩៤
- បានឃើញក្រឹត្យច្បាប់លេខ ៣០ ក្រប ចុះថ្ងៃទី ២០–១១–១៩៨៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ
- បានឃើញលិខិតលេខ ២៤៨ ជ.ខ.ម.ប ចុះថ្ងៃទី ៣០–៨–១៩៩០ របស់ខុទ្ទកាល័យមជ្ឈិមបក្ស
- បានឃើញលិខិតលេខ ១៩២–៩២ កជរស របស់ក្រុមប្រឹក្សាជាតិរណសិរ្សសាមគ្គីកសាងការពារមាតុភូមិកម្ពុជា ចុះថ្ងៃទី ១៥–០២–១៩៩២
- បានឃើញលិខិតលេខ ៥១៨ អយក.ចទម ចុះថ្ងៃទី ០៥–៤–១៩៩៤ របស់ក្រសួងអប់រំយុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ ចុះថ្ងៃទី ១៥–៦–១៩៩២ ស្តីពីការបើកសាលារៀន ចំណេះទូទៅឯកជន ។
- បានពិនិត្យពាក្យស្នើសុំរបស់លោក **តាយ ម៉ុច** ចុះថ្ងៃទី ០២–១២–១៩៩៥ ដោយមានចំណារ ឯកភាពរបស់មន្ទីរអប់រំ យុវជន និង កីឡា ក្រុងព្រះសីហនុ ចុះថ្ងៃទី ០៩–១២–១៩៩៥ និង ចំណារឯកភាពរបស់ឯកឧត្តម អភិបាលរងទី ៣ ក្រុងព្រះសីហនុ ចុះថ្ងៃទី ១២–១២–១៩៩៥
- តាមយោបល់ឯកភាពរបស់ នាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា

សំរេច

ប្រការ ១ : អនុញ្ញាតអោយលោក **គាយ ម៉ូច** បើកសាលាបឋមសិក្សាចំណេះទូទៅ ឯកជនចិន **គាន ហ្វារ** ដែលមានទីតាំងនៅដីឡូត៍លេខ ៤ ផ្លូវសាមគ្គី សង្កាត់លេខ ២ ខ័ណ្ឌមិត្តភាព ក្រុងព្រះសីហនុ ចាប់ពីឆ្នាំសិក្សា ១៩៩៥–៩៦ នេះតទៅ ។

ប្រការ ២ : សាលាបឋមសិក្សាចំណេះទូទៅឯកជនចិន **គាន ហ្វារ** ត្រូវនៅក្រោមការគ្រប់គ្រងរបស់មន្ទីរអប់រំ យុវជន និង កីឡា ក្រុងព្រះសីហនុ និង ត្រូវអនុវត្តកម្មវិធីសិក្សា និង សៀវភៅសិក្សាគ្រប់មុខវិជ្ជា តាមការអនុញ្ញាតរបស់ក្រសួងអប់រំ យុវជននិងកីឡា ។

ប្រការ ៣ : លោក **គាយ ម៉ូច** ត្រូវដឹកនាំគ្រប់គ្រង ចាត់តាំងគណៈគ្រប់គ្រងសាលារៀន និង គ្រូបង្រៀនដែលមានសមត្ថភាពគរុកោសល្យសមស្រប ព្រមទាំងអនុវត្តអោយត្រឹមត្រូវតាមការណែនាំរបស់ក្រសួងអប់រំ យុវជន និង កីឡា ។

ប្រការ ៤ : លោកប្រធានមន្ទីរ ក្រសួងអប់រំ យុវជន និង កីឡា លោកប្រធាននាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា លោកប្រធាននាយកដ្ឋានចាត់តាំង លោកប្រធានមន្ទីរអប់រំ យុវជន និង កីឡា ក្រុងព្រះសីហនុ លោកប្រធានការិយាល័យអប់រំ យុវជន និង កីឡា ខ័ណ្ឌមិត្តភាព លោក **គាយ ម៉ូច**និង សាលាបឋមសិក្សាឯកជនចិន **គាន ហ្វារ** មានភារកិច្ចអនុវត្តប្រកាសនេះ ។

ហត្ថលេខា និង ត្រា

តុល ឡោះ

* * *

៣_ទីស្តីការរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

ប្រកាស

ភ្នំពេញ , ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ១៩៩៦

ប្រកាសលេខ : ៣២៩ ប្រក.កសក.ចត

ស្តីពីការបង្កើតមជ្ឈមណ្ឌលឯកសារវិទ្យាសាស្ត្រ

បច្ចេកទេសកសិកម្ម

* * *

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត ១០៩៤-៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ១៩៨៤ ស្តីពីតួនាទីភារកិច្ច និង រចនាសម្ព័ន្ធចាត់តាំងរបស់ក្រសួងកសិកម្ម
- យោងតាមការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

សំរេច

មាត្រា ១ : បង្កើតមជ្ឈមណ្ឌលឯកសារវិទ្យាសាស្ត្របច្ចេកទេសកសិកម្ម Agricultural Scientific Docu mentation Centre (A S D C) ស្ថិតក្រោមការគ្រប់គ្រងផ្ទាល់ របស់មន្ទីរមានថ្នាក់ស្មើការិយាល័យ ។

មាត្រា ២ : មជ្ឈមណ្ឌលឯកសារវិទ្យាសាស្ត្របច្ចេកទេសកសិកម្មមានភារកិច្ច :

-គ្រប់គ្រងពត៌មានអំពីវិទ្យាសាស្ត្របច្ចេកទេសគ្រប់ផ្នែកក្នុងវិស័យកសិកម្ម ។

-តាមរយៈក្រសួងធ្វើទំនាក់ទំនងផ្លាស់ប្តូរទិន្នន័យបច្ចេកទេសកសិកម្មជាមួយមជ្ឈមណ្ឌលឯកសារកសិកម្មនៃប្រទេសនានាក្នុងសកលលោក និង អង្គការអន្តរជាតិ

-រ៉ាប់រងការរក្សា ការទុកដាក់ ឯកសារវិទ្យាសាស្ត្របច្ចេកទេសកសិកម្ម ធានាបាន សុវត្ថិភាព និង សំរបសំរួលធ្វើសេវាកម្មអំពីពត៌មាន ឬ ទិន្នន័យតាមសេចក្តីត្រូវការរបស់អ្នកបច្ចេកទេសកសិកម្មនិង អង្គភាពនានា ។

មាត្រា ៣ : មជ្ឈមណ្ឌលឯកសារវិទ្យាសាស្ត្របច្ចេកទេសកសិកម្ម ដឹកនាំដោយប្រធានមួយរូប និង អនុប្រធានមួយរូបជាជំនួយការ ។

មាត្រា ៤ : មជ្ឈមណ្ឌលឯកសារវិទ្យាសាស្ត្របច្ចេកទេសកសិកម្មរួមមាន ៤ ផ្នែក :

-ផ្នែករក្សាឯកសារ

-ផ្នែកវិភាគទិន្នន័យពត៌មាន

-ផ្នែកគំរោងការ និង សេវាកម្ម

-ផ្នែកប្រមូលលទ្ធផលស្រាវជ្រាវកសិកម្ម និង ភោគផលថ្មី

មាត្រា ៥ : ក្របខ័ណ្ឌនៃមជ្ឈមណ្ឌលឯកសារវិទ្យាសាស្ត្របច្ចេកទេសកសិកម្ម ត្រូវកំណត់ដោយ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

មាត្រា ៦ : អគ្គនាយកក្រសួង ប្រធានមន្ទីរ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋាន ផែនការស្ថិតិប្រធាននាយកដ្ឋាន គណនេយ្យ ហិរញ្ញវត្ថុនិងអង្គភាពពាក់ព័ន្ធនានាត្រូវ ទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះ តទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ឈា សុខ

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ១៩(

ប្រកាសលេខ : ៣២៨ ប្រក.កសក.ចត

ស្តីពីការបំបែកមូលដ្ឋានជាតិ

* * *

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត ១០៩៤-៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីតួនាទីភារកិច្ច និង រចនាសម្ព័ន្ធចាត់តាំងរបស់ក្រសួងកសិកម្ម
- បានឃើញអនុក្រឹត្យលេខ ២៨ អនក្រ ចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ១៩៩០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃអគ្គនាយកដ្ឋានចំការកៅស៊ូ
- បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ១៩៩៣ របស់រាជរដ្ឋាភិបាលជាតិបណ្តោះអាសន្ននៃកម្ពុជា ស្តីពីការដាក់អគ្គនាយកដ្ឋានចំការកៅស៊ូអោយស្ថិតនៅ ក្រោមការគ្រប់គ្រងផ្ទាល់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- តាមសំណើលេខ ២១២ អន.ចក ចុះថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ របស់អគ្គនាយកដ្ឋានចំការកៅស៊ូ ។

សំរេច

មាត្រា ១ : បំបែកមូលដ្ឋានចំការកៅស៊ូមេមត់ដែលមានផ្ទៃដីចំការកៅស៊ូ ៥.២៩៧,៦៤ ហិតា ជាពីរមូលដ្ឋានស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់ក្រុមហ៊ុនចំការកៅស៊ូមេមត់ នៃអគ្គនាយកដ្ឋានចំការកៅស៊ូដូចខាងក្រោម :

១-មូលដ្ឋានចំការកៅស៊ូមេមត់មានផ្ទៃដី ២.៨៧៨.៥២ ហិតា នឹងភូមិចំនួន ៤ : ភូមិដូងភូមិខ្នាយ ភូមិស្លា និង ភូមិឡាំបោរ ។

២-មូលដ្ឋានចំការកៅស៊ូកន្ទ្រើយមានផ្ទៃដី ២.៤១៩,១២ ហិតា នឹងភូមិចំនួន ៣ : ភូមិសំបួរ ភូមិក្រូច និង ភូមិក្នុងត្បូង ។

មាត្រា ២ : ក្រុមហ៊ុនចំការកៅស៊ូមេមត់មានភារកិច្ចរៀបចំចាត់តាំង បែងចែកមន្ត្រីដឹកនាំគ្រប់គ្រងមូលដ្ឋាន ផ្ទៃដីអាជីវកម្ម ព្រំប្រទល់ ភូមិ កំលាំងពលកម្ម ចលនៈទ្រព្យ អចលនៈទ្រព្យ អោយបានសមស្របដូចក្នុងមាត្រា ១ ដើម្បីអោយដំណើរការអនុវត្តន៍ទទួលបានលទ្ធផលល្អប្រសើរ ។

មាត្រា ៣ : អគ្គនាយកក្រសួង ប្រធានមន្ទីរ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានផែនការ ស្ថិតិ ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ ប្រធានអគ្គនាយកដ្ឋានចំការកៅស៊ូ ប្រធានក្រុមហ៊ុនចំការកៅស៊ូមេមត់ត្រូវទទួលបន្ទុកអនុវត្ត ប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ហត្ថលេខា និង ត្រា

តាវ សេងហួរ

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ១៩៩៦

ប្រកាសលេខ : ៣៣២ ប្រក.កសក

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

* * *

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ វិច្ឆិកា ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នសរកត ១០៩៤–៨៣ ចុះថ្ងៃទី ២៤ តុលា ១៩៩៤ ស្តីពីការ កែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញលិខិតលេខ ៤៦៣ សជណ.កស ចុះថ្ងៃទី ២០ មេសា ១៩៩៦ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីរាជរដ្ឋាភិបាលបានសំរេចយល់ព្រមជាគោលការណ៍ អោយក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និង នេសាទ ជួលទីតាំងស្ថានីយ៍ចិញ្ចឹមជ្រូក គីឡូម៉ែត្រលេខ ១១ និង ស្ថានីយ៍ចិញ្ចឹម មាន់ព្រៃកសំរោង
- បានឃើញកិច្ចសន្យា ស្តីពីការជួលទីតាំងមជ្ឈមណ្ឌលចិញ្ចឹមជ្រូក គីឡូម៉ែត្រលេខ ១១ រវាង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និង ក្រុមហ៊ុន C.P. CAMBODIA Co., Ltd ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ១៩៩៦
- បានឃើញកិច្ចសន្យា ស្តីពីការជួលទីតាំងមជ្ឈមណ្ឌលចិញ្ចឹមមាន់ព្រៃកសំរោង រវាង ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និង ក្រុមហ៊ុន C.P. CAMBODIA Co., Ltd ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ១៩៩៦

សម្រេច

